ដំណោះស្រាយការការពារ
PROTECTION

# AIA សម្រាប់ជីវិត

# ការពារអនាគតមនុស្សជាទីស្រលាញ់របស់អ្នក

## Protecting the Future of Those You Live for



aia.com.kh

# ដំណោះស្រាយការការពារ

នៅចំណុចណាមួយក្នុងជីវិតរបស់យើងគ្រប់ៗរូប នឹងមានជួបប្រទះហេតុការណ៍ល្អ និងអាក្រក់ ឬនូវភាពជោគជ័យ និង បរាជ័យភាព ឬ សប្បាយរីករាយ និងទុក្ខព្រួយ។ នៅពេលដែលព្រឹត្តិការណ៍ល្អៗកើតឡើងនៅក្នុងជីវិតរបស់យើង យើងរីករាយចំពោះព្រឹត្តិការណ៍ទាំងនោះ ហើយសង្ឃឹមថាព្រឹត្តិការណ៍ទាំងនោះនឹងនៅតែបន្តកើតឡើង។ប៉ុន្តែដោយសារតែយើងពុំអាចព្យាករណ៍ទុកមុននូវអ្វីៗដែលនឹងកើតឡើងក្នុងឆាកជីវិតរបស់យើង យើងបានត្រឹមតែសង្ឃឹមថានឹងជួបតែរឿងល្អៗ ហើយត្រៀមខ្លួនដើម្បីប្រឈមមុខនឹងព្រឹត្តការណ៍ដែលពុំអាចស្មានទុកមុន។

យើងខ្ញុំនាំយកនូវដំណោះស្រាយដែលស័ក្តិសមបំផុត សម្រាប់តម្រូវការរបស់អ្នក។ យើងខ្ញុំសូមណែនាំ AIA សម្រាប់ជីវិត ដែលជាគម្រោងធានារ៉ាប់រងអាយុជីវិតដ៏ពេញលេញមួយសម្រាប់ការការពារហិរញ្ញវត្ថុ និងការសន្សំរយៈពេលវែង ដែលអនុញ្ញាតឲ្យអ្នកអាចជ្រើសរើសកម្រិតនៃការការពារ និងការសន្សំដើម្បីឲ្យសមស្របទៅនឹងតម្រូវការរបស់អ្នកទៅតាមដំណាក់កាលនៃជីវិត។



# ការពារខ្លួនអ្នក និងភាពសុខដុមរមនារបស់មនុស្សជាទីស្រលាញ់របស់អ្នក

អ្នកអាចការពារខ្លួនអ្នក និងមនុស្សជាទីស្រលាញ់របស់អ្នកជាមួយនឹងបុព្វលាភធានារ៉ាប់រងដ៏សមរម្យ

## AIA សម្រាប់ជីវិត

### អត្ថប្រយោជន៍ការពារគ្រួសារ

ការការពារក្នុងករណីទទួលមរណភាព

ធានាថាគ្រួសាររបស់អ្នកនឹងទទួលបានការការពារ ហើយតម្រូវការផ្នែកហិរញ្ញវត្ថុរបស់គ្រួសារអ្នកនឹងត្រូវបានរ៉ាប់រង បើទោះបីជាអ្នកមិនអាចបន្តរស់នៅជាមួយពួកគេបាន។

## ផលិតផលធានារ៉ាប់រងបន្ថែម

### 1 អត្ថប្រយោជន៍លើការស្តារនីតិសម្បទា

ការការពារក្នុងករណីមានពិការភាព

អ្នកនឹងទទួលបានទឹកប្រាក់ធានារ៉ាប់រង ប្រសិនបើអ្នកបានជួបប្រទះនូវព្រឹត្តការណ៍អកុសលដែលបណ្តាលឱ្យអ្នកមានពិការភាព ឬបាត់បង់ផ្នែកចក្ខុវិញ្ញាណរបស់អ្នក។

### 2 អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ

ការការពារបន្ថែមចំពោះគ្រោះថ្នាក់ចៃដន្យ

បន្ថែមកម្រិតការការពាររបស់អ្នក ដើម្បីធានាថាអ្នក និងមនុស្សជាទីស្រលាញ់របស់អ្នកនឹងទទួលការការពារផ្នែកហិរញ្ញវត្ថុ ប្រសិនបើអ្នកបានជួបប្រទះនូវព្រឹត្តការណ៍អកុសលណាមួយដោយចៃដន្យ។

### 3 អត្ថប្រយោជន៍ការលើកលែងការបង់បុព្វលាភធានារ៉ាប់រង (ម្ចាស់បណ្ណសន្យារ៉ាប់រង)

ការការពារពីការមិនអាចបន្តបង់បុព្វលាភធានារ៉ាប់រងដោយអចេតនា

ក្នុងករណីអ្នកបានជួបប្រទះនូវព្រឹត្តការណ៍អកុសលណាមួយ ការការពាររបស់អ្នកនឹងនៅតែបន្ត ទោះបីជាអ្នកមិនមានលទ្ធភាពក្នុងការបន្តការបង់បុព្វលាភធានារ៉ាប់រងក៏ដោយ។

### 4 អត្ថប្រយោជន៍ការលើកលែងការបង់បុព្វលាភធានារ៉ាប់រង (អ្នកត្រូវបានធានារ៉ាប់រង)

ការការពារពីការមិនអាចបន្តបង់បុព្វលាភធានារ៉ាប់រងដោយអចេតនា

ក្នុងករណីអ្នកបានជួបប្រទះនូវព្រឹត្តការណ៍អកុសលណាមួយ ការការពាររបស់អ្នកនឹងនៅតែបន្ត ទោះបីជាអ្នកមិនមានលទ្ធភាពក្នុងការបន្តការបង់បុព្វលាភធានារ៉ាប់រងក៏ដោយ។

### 5 អត្ថប្រយោជន៍សម្រាប់ការព្យាបាល

ការការពារលើជំងឺធ្ងន់ធ្ងរ

ធានារ៉ាប់រងទៅលើការចំណាយក្នុងការព្យាបាល ស្ថានភាពជំងឺរហូតដល់ 26 ប្រភេទនៃជំងឺ មហារីក ជំងឺខួរក្បាល ជំងឺថ្លើម ជំងឺសួត ជំងឺតម្រងនោម ជំងឺបេះដូងនិងប្រព័ន្ធសរសៃឈាមពីដំណាក់កាល ដំបូង រហូតដល់ ដំណាក់កាលចុងក្រោយ ព្រមទាំងការផ្លាស់ប្តូរសរីរាង្គសំខាន់ៗ ផងដែរ។ អ្នកនឹងអាចទទួលបានទឹកប្រាក់អត្ថប្រយោជន៍ សម្រាប់ការព្យាបាលទាំងនៅ មន្ទីរពេទ្យ ក្នុងស្រុក និងនៅបរទេស។ អ្វីដែលអ្នកគួរតែផ្តោតសំខាន់នោះ គឺការមើលថែទាំខ្លួនឱ្យបានឆាប់ជាសះស្បើយជាជាងព្រួយបារម្ភអំពីការចំណាយទៅលើការ ព្យាបាលរបស់អ្នក។

### 6 អត្ថប្រយោជន៍បន្ថែមលើគ្រោះថ្នាក់

ការការពារលើការរងរបួសដោយគ្រោះថ្នាក់ចៃដន្យ

ផលិតផលធានារ៉ាប់រងបន្ថែមនេះ បន្ថែមការការពារដល់អ្នកក្នុងករណីទទួលគ្រោះថ្នាក់ចៃដន្យ និង ជំនួយក្នុងគ្រាអាសន្ននៅក្រៅប្រទេស។

## ជម្រើសអត្ថប្រយោជន៍បន្ថែមលើការសន្សំប្រាក់

### អត្ថប្រយោជន៍ការពារដែលនឹងទទួលបានប្រាក់ត្រលប់មកវិញ

ប្រសិនបើអ្នកចង់មានប្រាក់សន្សំមួយចំនួនជាមួយនឹងគម្រោងធានារ៉ាប់រងរបស់អ្នក អ្នកអាចជ្រើសរើសយកជម្រើសនេះ ដែលអនុញ្ញាតឱ្យអ្នកអាចទទួលបុព្វលាភធានារ៉ាប់រងរបស់អ្នកមួយផ្នែកមកវិញនៅចុងបញ្ចប់នៃគម្រោងធានារ៉ាប់រង ប្រសិនបើ មិនមានការទាមទារសំណងណាមួយរហូតដល់ពេលបញ្ចប់គម្រោងអត្ថប្រយោជន៍របស់អ្នក។

### អត្ថប្រយោជន៍ការពារដែលទទួលបានប្រាក់ និងការប្រាក់ត្រលប់មកវិញ

ប្រសិនបើអ្នកចង់មានប្រាក់សន្សំមួយចំនួនជាមួយនឹងគម្រោងធានារ៉ាប់រងរបស់អ្នក ហើយទទួលបានការប្រាក់បន្ថែមទៀត នោះ អ្នកអាចជ្រើសរើសយកជម្រើសនេះដែលអនុញ្ញាតឱ្យអ្នកអាចទទួលបានបុព្វលាភធានារ៉ាប់រងរបស់អ្នកមកវិញ ជាមួយនឹងការប្រាក់នៅចុងបញ្ចប់នៃគម្រោងធានារ៉ាប់រង ប្រសិនបើមិនមានការទាមទារសំណងណាមួយរហូតដល់ពេលបញ្ចប់។

# ដំណោះស្រាយដែលសមស្របតាមតម្រូវការ និងលទ្ធភាពរបស់អ្នក សម្រាប់គ្រប់ដំណាក់កាលនៃជីវិត

តម្រូវការរបស់អ្នកអាចនឹងខុសគ្នាពីអ្នកដទៃ។ ដូច្នេះអ្នកអាចជ្រើសរើសយកប្រភេទអត្ថប្រយោជន៍ រយៈពេលនៃការធានារ៉ាប់រង ជម្រើសនៃការសន្សំ និងរយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រងដែលសមស្របទៅនឹងតម្រូវការ និងលទ្ធភាពរបស់អ្នក។

ស្របពេលដែលស្ថានភាពជីវិតរបស់អ្នកផ្លាស់ប្តូរ តម្រូវការលើធានារ៉ាប់រងរបស់អ្នកក៏មានការប្រែប្រួល ដូចនេះហើយទើបគម្រោង AIA សម្រាប់ជីវិត អនុញ្ញាតឲ្យអ្នកអាចផ្លាស់ប្តូរអត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រងបានតម្រូវការរបស់អ្នក។



## ដំណើរការនៃគម្រោងអត្ថប្រយោជន៍នេះ

លោកអ្នកគ្រាន់តែជ្រើសរើសអត្ថប្រយោជន៍ រយៈពេលនៃការធានារ៉ាប់រង និងរយៈពេលបង់បុព្វលាភធានារ៉ាប់រងសម្រាប់បណ្ណសន្យារ៉ាប់រងរបស់អ្នក។ បន្ទាប់មកយើងនឹងបង្កើតគណនី ធានារ៉ាប់រងមួយសម្រាប់អ្នក ហើយដាក់បុព្វលាភធានារ៉ាប់រងដែលអ្នកបានបង់ បញ្ចូលទៅក្នុងគណនីនោះ។

យើងនឹងដាក់បញ្ចូលការប្រាក់ទៅក្នុងគណនីរបស់អ្នក ដោយផ្អែកលើចំណូលការប្រាក់ដែលរកបាន។ ការប្រាក់ និងអត្រាការប្រាក់ដែលអ្នកអាច ទទួលបានពីគម្រោងធានារ៉ាប់រងរបស់អ្នក មិនមានកម្រិតថេរនោះទេ។ យើងនឹងកំណត់អត្រាការប្រាក់សម្រាប់គម្រោងធានារ៉ាប់រងរបស់អ្នកតាមពេលវេលាសមស្រប។

យើងនឹងទូទាត់កម្រៃធានារ៉ាប់រងជារៀងរាល់ខែ ពីគណនីធានារ៉ាប់រងរបស់អ្នក អាស្រ័យលើកត្តាផ្សេងៗនៃគម្រោងធានារ៉ាប់រងនោះ (ឧ. ប្រភេទអត្ថប្រយោជន៍ បរិមាណអត្ថប្រយោជន៍នានាដែលអ្នកបានជ្រើសរើស...) ព្រមទាំងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកផងដែរ (ឧ. អាយុ ស្ថានភាព សុខភាព...)។ យើងអាចធ្វើការកែប្រែកម្រៃបណ្ណសន្យារ៉ាប់រងនៃគម្រោងធានារ៉ាប់រងរបស់អ្នកសារឡើងវិញ នៅកំឡុងពេលណាមួយ យោងតាម ស្ថានភាពប្រតិបត្តិការនៅកម្ពុជា។

ប្រសិនបើអ្នកបានធ្វើការទាមទារសំណងនៅកំឡុងពេលណាមួយនៃគម្រោងធានារ៉ាប់រងរបស់អ្នក ហើយសមតុល្យគណនីរបស់អ្នកតូចជាងចំនួនទឹកប្រាក់អត្ថប្រយោជន៍ដែលអ្នកបានជ្រើសរើស នោះយើងនឹងបន្ថែមទឹកប្រាក់លើសមតុល្យរបស់អ្នកឲ្យស្មើនឹងទឹកប្រាក់អត្ថប្រយោជន៍នោះ ដើម្បីផ្តល់ជា សំណងជូនអ្នក។

អ្នកអាចស្នើសុំដកទឹកប្រាក់ទាំងអស់ ឬដោយផ្អែកបាន ពីគណនីរបស់អ្នកមុនពេលចុងបញ្ចប់នៃរយៈពេលធានារ៉ាប់រង។ គម្រោងរបស់អ្នកនឹងនៅ តែបន្តរហូតដល់ចុងបញ្ចប់នៃគម្រោងដែលអ្នកបានជ្រើសរើស ប្រសិនបើទឹកប្រាក់ក្នុងគណនីរបស់អ្នក មិនអវិជ្ជមាន។ យើងនឹងផ្តល់ជូនអ្នកនូវទឹក ប្រាក់ទាំងអស់ក្នុងគណនីរបស់អ្នក នៅចុងបញ្ចប់នៃគម្រោង។

# AIA សម្រាប់ជីវិត

តារាទើបតែរៀបការថ្មីៗ។ គាត់បានទិញគម្រោងអត្ថប្រយោជន៍ AIA សម្រាប់ជីវិត ដើម្បីការពារខ្លួន និងប្រពន្ធរបស់គាត់ ហើយកំណត់យកគោលដៅសន្សំ ចំនួន 10,000 ដុល្លារ



| | |
|---|---|
| អត្ថប្រយោជន៍សម្រាប់ព្យាបាលជំងឺ | US$ 10,000 |
| អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា | US$ 10,000 |
| អត្ថប្រយោជន៍ការពារគ្រួសារ | US$ 10,000 |
| អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ | US$ 30,000 |
| គោលដៅសន្សំ | US$ 10,000 |
| បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ | US$ 352 |

តារាក្លាយជាឪពុក ហើយគាត់បានបន្ថែមការការពារទ្វេដងសម្រាប់ គាត់ និងក្រុមគ្រួសាររបស់គាត់។



| | |
|---|---|
| អត្ថប្រយោជន៍សម្រាប់ព្យាបាលជំងឺ | US$ 20,000 ▲ |
| អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា | US$ 20,000 ▲ |
| អត្ថប្រយោជន៍ការពារគ្រួសារ | US$ 20,000 ▲ |
| អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ | US$ 60,000 ▲ |
| គោលដៅសន្សំ | US$ 10,000 |
| បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ | US$ 474 ▲ |

តារាបានចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន។ គាត់បានកាត់បន្ថយគោលដៅសន្សំ និង បុព្វលាភធានារ៉ាប់រងរបស់គាត់ តែរក្សា អត្ថប្រយោជន៍ការពារឲ្យនៅដដែល។



| | |
|---|---|
| អត្ថប្រយោជន៍សម្រាប់ព្យាបាលជំងឺ | US$ 20,000 |
| អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា | US$ 20,000 |
| អត្ថប្រយោជន៍ការពារគ្រួសារ | US$ 20,000 |
| អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ | US$ 60,000 |
| គោលដៅសន្សំ | US$ 3,000 ▼ |
| បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ | US$ 314 ▼ |

តារាត្រូវបានពិនិត្យឃើញថាមានជំងឺមហារីកដំណាក់ កាលដំបូង។ គាត់ទទួលបានប្រាក់អត្ថប្រយោជន៍ ចំនួន 5,000 ដុល្លារពីគម្រោងអត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ។ គាត់បានកាត់បន្ថយប្រាក់បុព្វលាភ និងគោលដៅ សន្សំបន្ទាប់ពីបានទទួលអត្ថប្រយោជន៍នេះ។




| | |
|---|---|
| អត្ថប្រយោជន៍សម្រាប់ព្យាបាលជំងឺ | US$ 15,000 ▼ |
| អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា | US$ 15,000 ▼ |
| អត្ថប្រយោជន៍ការពារគ្រួសារ | US$ 15,000 ▼ |
| អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ | US$ 55,000 ▼ |
| គោលដៅសន្សំ | - |
| បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ | US$ 249 ▼ |

តារាបានទទួលមរណៈភាពដោយសារគ្រោះថ្នាក់។ គ្រួសារតារាទទួលបានប្រាក់អត្ថប្រយោជន៍ ចំនួន 55,000 ដុល្លារ ពីគម្រោងអត្ថប្រយោជន៍របស់គាត់ ដើម្បីរក្សានូវស្ថិរភាពជីវភាពក្រុមគ្រួសារគាត់ ហើយគម្រោងរបស់គាត់ត្រូវបានបញ្ចប់។



| | |
|---|---|
| អត្ថប្រយោជន៍សម្រាប់ព្យាបាលជំងឺ | - |
| អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា | - |
| អត្ថប្រយោជន៍ការពារគ្រួសារ | - |
| អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ | - |
| គោលដៅសន្សំ | - |
| បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ | - |

បញ្ចប់គម្រោង

តាមរយៈការជួយជ្រោមជ្រែងពីអត្ថប្រយោជន៍ការពារគ្រួសាររបស់តារា កូនរបស់គាត់បានបន្ត និងបញ្ចប់ពីការសិក្សានៅ សាកលវិទ្យាល័យ។



## ករណីមិនធានាលើការធ្វើអត្តឃាត និងករណីមិនធានាទូទៅ

ការទទួលខុសត្រូវរបស់យើង មានកំណត់ត្រឹមតម្លៃគណនីបណ្ណសន្យារ៉ាប់រងដកបំណុល ប្រសិនបើមានការបាត់បង់ជីវិតដោយកត្តាណាមួយដូចខាងក្រោម÷

(i) ការធ្វើអត្តឃាត ការធ្វើឱ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្មារតីប្រក្រតី ឬមិនប្រក្រតីក៏ដោយក្នុងរយៈពេល 2 (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្តើម ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេឬ

(ii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(iii) វីរុសហ៊ីវ និង/ ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ ឬការផ្លាស់ប្តូរ ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

(iv) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬការបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងខ និងលក្ខខណ្ឌជាធរមាន

## ករណីមិនធានាលើការស្លាប់ធានារ៉ាប់រងពិការភាព/ អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ/ អត្ថប្រយោជន៍ការលើកលែងការបង់បុព្វលាភធានារ៉ាប់រង (ម្ចាស់បណ្ណសន្យារ៉ាប់រង/ អ្នកត្រូវបានធានារ៉ាប់រង)

ផលិតផលធានារ៉ាប់រងបន្ថែមទាំងនេះ មិនធានាលើ មរណភាព ឬពិការភាពណាដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយហេតុការណ៍ណាមួយដូចខាងក្រោមឡើយ÷

(i) ការប្រឈមនឹងគ្រោះថ្នាក់ ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្មារតីប្រក្រតី ឬមិនប្រក្រតីក៏ដោយ

(ii) ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ

(iii) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន្ត ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ តាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(iv) ពុំមានអត្ថប្រយោជន៍ណាមួយ នឹងត្រូវផ្តល់ជូនសម្រាប់ពិការភាព ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្តើមនៃផលិតផលធានារ៉ាប់រងបន្ថែម ដោយយកកាលបរិច្ឆេទចុងក្រោយគេ ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព។

(v) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(vi) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬការបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងខ និងលក្ខខណ្ឌជាធរមាន

## ករណីមិនធានា សម្រាប់អត្ថប្រយោជន៍ការព្យាបាលជំងឺធ្ងន់ធ្ងរ

ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើ÷

(i) ជំងឺ ឬការវះកាត់ណាមួយក្រៅពីការធ្វើរោគវិនិច្ឆ័យ ឬការវះកាត់សម្រាប់អាការៈជំងឺធ្ងន់ធ្ងរដូចបានកំណត់ក្នុងខ និងលក្ខខណ្ឌនេះ។

(ii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ថាជាជំងឺ/វះកាត់ក្រុមទី 1 ត្រូវបានបង្ហាញឱ្យឃើញមុន ឬក្នុងកំឡុងពេល 120 (មួយរយម្ភៃ) ថ្ងៃរាប់ចាប់ពីថ្ងៃនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬថ្ងៃចាប់ផ្តើម នៃផលិតផលធានារ៉ាប់រងបន្ថែម ដោយយកកាលបរិច្ឆេទចុងក្រោយគេ

(iii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ថាជា ជំងឺ/វះកាត់ក្រុមទី 2 បានកើតឡើងមុន ឬក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ

(iv) អាការៈជំងឺធ្ងន់ធ្ងរកើតឡើងដោយផ្ទាល់ ឬប្រយោលពីស្ថានភាពមុនពេលធានារ៉ាប់រងដូចបានកំណត់ ដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្តើមនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។

(v) អាការៈជំងឺធ្ងន់ធ្ងរ ដែលតាមគំនិតរបស់យើងខ្ញុំ កើតមានដោយផ្ទាល់ ឬដោយប្រយោលពីវត្តមាននៃ មេរោគអេដស៍ (AIDS ឬ HIV) និងលក្ខខណ្ឌផ្សេងៗដែលពាក់ព័ន្ធ។ យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការតម្រូវឱ្យអ្នកត្រូវបានធានារ៉ាប់រងទៅពិនិត្យឈាមរកមេរោគអេដស៍ដែលជាលក្ខខណ្ឌដំបូងបង្អស់ក្នុងការទទួលយកការទាមទារសំណងណាមួយ។ករណីលើកលែងគឺនៅពេលដែលការឆ្លងមេរោគអេដស៍ដោយសារការផ្តល់ឈាម ដូចបានកំណត់ក្នុងផលិតផលធានារ៉ាប់រងបន្ថែមនេះ។ ចំពោះគោលបំណងផលិតផលធានារ៉ាប់រងបន្ថែមនេះ

(ក) និយមន័យនៃ ជំងឺអេដស៍ (AIDS) ត្រូវតែជានិយមន័យដែលត្រូវបានប្រើដោយអង្គការសុខភាពពិភពលោកក្នុងឆ្នាំ 1987 ឬការកែប្រែណាមួយក្រោយមកទៀតទៅលើនិយមន័យនោះដោយអង្គការសុខភាពពិភពលោក។

(ខ) ការឆ្លងមេរោគនេះ ត្រូវចាត់ទុកថាបានកើតឡើងនៅពេលដែលការពិនិត្យឈាម ឬការពិនិត្យផ្សេងៗដែលពាក់ព័ន្ធ ហើយដែលតាមយោបល់របស់យើងខ្ញុំ បង្ហាញថាមានផ្ទុកវីរុសហ៊ីវ ឬអង់ទីករប្រឆាំងមេរោគនេះ។

(vi) អាការៈជំងឺធ្ងន់ធ្ងរមានកម្រិតដូចគ្នា នឹងជំងឺធ្ងន់ធ្ងរដែលធ្លាប់បានទាមទារសំណងពីមុន

(vii) រាល់ការធ្វើរោគវិនិច្ឆ័យលើអាការៈជំងឺធ្ងន់ធ្ងរណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីការផ្តល់កំណើតមិនត្រឹមត្រូវ ឬដោយមេរោគពីកំណើត ដែលត្រូវបានពិនិត្យឃើញ ឬធ្វើរោគវិនិច្ឆ័យមុនពេលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ

(viii) រាល់អាការៈជំងឺធ្ងន់ធ្ងរដែលកើតឡើងដោយសារការបង្ករឡើយដោយខ្លួនឯងផ្ទាល់

(ix) រាល់អាការៈជំងឺធ្ងន់ធ្ងរដែល កើតឡើងដោយផ្ទាល់ពីការពិសារគ្រឿងស្រវឹង ឬប្រើប្រាស់ថ្នាំញៀនហួសកម្រិត ឬ

(x) អាការៈជំងឺធ្ងន់ធ្ងរណាមួយដែលបណ្តាលមកពីស្ថានភាពផ្លូវកាយ ឬផ្លូវចិត្តដែលបានកើតមានមុនកាល បរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្តើមនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ (ដោយយកកាលបរិច្ឆេទណាចុងក្រោយគេ) ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំធានារ៉ាប់រង ឬរបាយការណ៍សុខភាព។

(xi) ការបរិច្ចាគផ្នែកណាមួយនៃរាងកាយរបស់អ្នកដែលត្រូវបានធានារ៉ាប់រង

## ករណីមិនធានាសម្រាប់អត្ថប្រយោជន៍បន្ថែមលើគ្រោះថ្នាក់

ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើមរណភាព ពិការភាព ការរលាក ឬការសម្រាកក្នុងមន្ទីរពេទ្យណាដែលបង្កឡើងដោយផ្ទាល់ ឬ ដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយហេតុការណ៍ណាមួយខាងក្រោមឡើយ÷

(i) ការប្រឈមនឹងគ្រោះថ្នាក់ ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ

(ii) ការចូលបម្រើក្នុងជួរកងទ័ពក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ

(iii) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើក លែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(iv) ពុំមានអត្ថប្រយោជន៍ណាមួយនឹងត្រូវផ្តល់ជូនសម្រាប់ ពិការភាព ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលកើតមានមុនកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្តើមនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព។

(v) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(vi) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬការបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងខ និងលក្ខខណ្ឌជាធរមាន

## សម្រាប់សេវាជំនួយគ្រាអាសន្ននៅក្រៅប្រទេស

ការព្យាបាល ចំណុច លក្ខខណ្ឌ ឬសកម្មភាព និងចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងចំណុចទាំងនេះនឹងមិនត្រូវបានធានានោះទេ÷

(i) ចំណាយណាមួយ ដែលកើតពីស្ថានភាពមុនពេលធានារ៉ាប់រង

(ii) ករណីធ្វើការជម្លៀសទៅមន្ទីរពេទ្យគ្រាអាសន្នសម្រាប់លក្ខខណ្ឌសុខភាពតែមួយរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងរយៈពេលមួយឆ្នាំនៃរយៈពេលធានារបស់  បណ្ណសន្យារ៉ាប់រង

(iii) ការចំណាយណាដែលមិនត្រូវបានធានា ដោយផលិត ផលធានារ៉ាប់រងបន្ថែមនេះ ហើយមិនត្រូវបានអនុម័តដោយអ្នកផ្គត់ផ្គង់ជាមុនដោយលាយលក្ខណ៍អក្សរ ឬមិនបានរៀបចំដោយអ្នកផ្តល់សេវា។ ករណីមិនធានានេះ នឹងមិនត្រូវអនុវត្តលើការជម្លៀសទៅកាន់មន្ទីរពេទ្យនាគ្រាអាសន្នពីតំបន់ដាច់ស្រយាល នៅពេលដែលមិនអាចទាក់ទងអ្នកផ្តល់សេវាបានជាមុន ហើយការយឺតយ៉ាវអាចបង្កឲ្យអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬរងគ្រោះ។

(iv) ករណីណាដែលកើតឡើង នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងចិតក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរយៈចំងាយ 150 គីឡូម៉ែត្រនៃប្រទេសនេះ

(v) ចំណាយណាមួយ សម្រាប់អ្នកត្រូវបានធានារ៉ាប់រង ដែលធ្វើដំណើរទៅក្រៅព្រះរាជាណាចក្រកម្ពុជា ឬក្នុងរយៈចំងាយ 150 គីឡូម៉ែត្រពីប្រទេសនេះ ដែលមិនស្របតាមការផ្តល់ដំបូន្មានរបស់គ្រូពេទ្យ ឬក្នុងគោលបំណងស្វែងរកការព្យាបាល ឬសម្រាកដើម្បីជាសះស្បើយក្រោយពីទទួលគ្រោះថ្នាក់រួចហើយ ព្យាបាលជំងឺ ឬស្ថានភាពមុនពេលធានារ៉ាប់រង។

(vi) ការចំណាយណាមួយ សម្រាប់ការជម្លៀសទៅមន្ទីរពេទ្រគ្រាអាសន្ន ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង មិនមានលក្ខខណ្ឌវេជ្ជសាស្ត្រធ្ងន់ធ្ងរ និង/ ឬវេជ្ជបណ្ឌិតរបស់អ្នកផ្តល់សេវាគិតថា អ្នកត្រូវបានធានារ៉ាប់រងអាចទទួលបានការព្យាបាលក្នុងប្រទេសកើតហេតុ ឬអាចរងចាំទទួលការព្យាបាល នៅពេលត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ។

(vii) ចំណាយណាមួយ សម្រាប់ការជម្លៀសទៅមន្ទីរពេទ្យ ដែលគ្រូពេទ្យរបស់អ្នកផ្តល់សេវា គិតថាអ្នកត្រូវបានធានារ៉ាប់រង អាចធ្វើដំណើរជាលក្ខណៈអ្នកធ្វើដំណើរធម្មតាដោយមិនត្រូវការសេវាវេជ្ជសាស្ត្រភ្ជាប់ជាមួយ។

(viii) ការព្យាបាល ឬចំណាយណាមួយពាក់ព័ន្ធនឹងការសម្រាលកូន ការរលូតកូន ឬការមានផ្ទៃពោះ។ ការលើកលែងនេះនឹងមិនអនុវត្តលើការមានផ្ទៃពោះខុសប្រក្រតី ឬផលវិបាកក្នុងកំឡុងពេលមានផ្ទៃពោះធ្ងន់ធ្ងរ ដែលបង្កគ្រោះថ្នាក់ដល់ម្តាយ និង/ឬកូនដែលមិនទាន់កើតក្នុងរយៈពេល 24 សប្តាហ៍ដំបូងនៃការមានផ្ទៃពោះ។

(ix) ចំណាយណាមួយដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ឬរបួសដែលកើតឡើងខណៈដែលអ្នកត្រូវបានធានារ៉ាប់រងបានចូលរួមសកម្មភាពដូចជា ការចូលមើលជ្រលងភ្នំ ឡើងភ្នំ ឡើងលើភ្នំតាមជញ្ជាំងថ្មភ្នំដែលទាមទារឲ្យប្រើគន្លងផ្លូវច្បាស់លាស់ ឬខ្សែពួរ មើលជ្រលងភ្នំ ហក់លោតពីទីអាកាសខ្ពស់ លោតឆាត់យោង លោតពីទីខ្ពស់ដោយប្រើខ្សែពួរ ជិះបាឡុង ជិះឧបករណ៍សំកាំងលើអាកាស ការជ្រមុជជ្រៅក្នុងសមុទ្រដោយប្រើម្ហូកការពារនិងភ្ជាប់ទុយោដកដង្ហើម ការហ្វឹកហាត់ក្បាច់គុណ ការប្រកួតប្រជែងប្រណាំងផ្សេងៗដែលក្រៅពីការប្រណាំងដោយប្រើជើង ឬសកម្មភាពកីឡាផ្សេងៗដែលជាលក្ខណៈអាជីព ឬមានការឧបត្ថម្ភ។

(x) ចំណាយណាមួយដែលកើតឡើងសម្រាប់ជំងឺផ្នែកសតិអារម្មណ៍ ជំងឺផ្លូវចិត្ត ឬជំងឺវិកលចរិក។

(xi) ចំណាយណាមួយ ដែលកើតឡើងដោយលទ្ធផលនៃការបង្ករបួសខ្លួនឯង អត្តឃាត ការប្រើប្រាស់គ្រឿងញៀន ការប្រើប្រាស់គ្រឿងស្រវឹង ឬជំងឺកាមរោគ។

(xii) ចំណាយណាមួយ ដែលកើតឡើងដោយជំងឺអេដស៍ ឬលក្ខខណ្ឌដែលពាក់ព័ន្ធនឹងជំងឺនេះ។

(xiii) ចំណាយណាមួយ ដែលទាក់ទងនឹងអ្នកត្រូវបានធានារ៉ាប់រង ធ្វើការធ្វើដំណើរផ្លូវអាកាសតាមទម្រង់ផ្សេងៗ លើកលែងតែជាអ្នកធ្វើដំណើរ តាមអាកាសដែលមានជើងហោះហើរត្រឹមត្រូវ ឬតាមយន្តហោះដែលធ្វើដំណើរតាមផ្លូវអាកាសមានអាជ្ញាបណ្ណត្រឹមត្រូវ។

(xiv) ចំណាយណាមួយ ដែលអ្នកត្រូវបានធានារ៉ាប់រងពាក់ព័ន្ធនឹងការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស។

(xv) ការចំណាយណាមួយ ដែលពាក់ព័ន្ធនឹងការព្យាបាលដែលធ្វើ ឬបញ្ជាដោយគ្រូពេទ្យដែលមិនបានចុះបញ្ជីការ ទៅតាមបទដ្ឋានការអនុវត្តវេជ្ជសាស្ត្រក្នុងប្រទេសដែលធ្វើការព្យាបាល។

(xvi) ចំណាយណាមួយ ដែលកើតឡើងដោយសារតែអ្នកត្រូវបានធានារ៉ាប់រង បានចូលរួមបំពេញសេវាកងទ័ព ឬនគរបាលនៃប្រទេសណាមួយ ការចូលរួមសង្គ្រាមយ៉ាងសកម្ម (ប្រកាស ឬមិនប្រកាសក្តី) ការឈ្លានពាន សកម្មភាពសត្រូវនឹងជនបរទេស ភាពជាសត្រូវសង្គ្រាមស៊ីវិល ការបះបោល កុបកម្ម បដិវត្តន៍ ឬចលាចល។

(xvii) ចំណាយណាមួយដែលកើតពីប្រតិកម្ម ឬចំហាយសាយភាពជាតិវិទ្យុសកម្ម

(xviii) ចំណាយណាមួយដែលកើតឡើងសម្រាប់ ឬមកពីលទ្ធផលនៃសកម្មភាព ដែលតម្រូវលើនាវា ឬវេទិការោងចក្រប្រេង ឬនៅទីតាំងច្រាំងស្រដៀងគ្នា។

(xix) ចំណាយណាមួយដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុច្រើនជាង 70 ឆ្នាំ គិតត្រឹមថ្ងៃដែលទទួលការព្យាបាល។

(xx) ចំណាយណាមួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ឬបញ្ចេញ ឬការគម្រាមកំហែងពីអាវុធនុយក្លេអ៊ែរ ឬសារធាតុគីមី ឬជីវ ដែលរួមមានតែមិនកម្រិតត្រឹមចំណាយដែលបង្កដោយ ឬបង្កឲ្យមានដោយសកម្មភាពភេរវកម្ម ឬសង្គ្រាម ដោយមិនគិតពីហេតុបង្កណាមួយ ។

**ភ្នំពេញ**

ជាន់ទី 12 អគារ EXCHANGE SQUARE ផ្លូវលេខ 106 កែងផ្លូវលេខ 61
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ជាន់ទី 8 និងទី 9 អគារ CITY TOWER លេខ 321 មហាវិថីម៉ៅសេទុង
សង្កាត់ផ្សារដេប៉ូ 1 ខណ្ឌទួលគោក រាជធានីភ្នំពេញ

**សៀមរាប**

អគារលេខ 29 និង 30 ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង
សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**បាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ា ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**កំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**កំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

AIA.COM.KH | AIA CAMBODIA | 086 999 242